ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៤៧២៧ អពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តប្រមូលពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូន

អនុលោមតាមប្រកាសលេខ ២៧៣ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា, ប្រកាសលេខ ០០១ សហវ.ប្រក.អពដ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីមូលដ្ឋានគិតពន្ធប្រថាប់ត្រា ចំពោះមធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ និងប្រកាសលេខ ១១៤៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងដើម្បីធានាដល់ការផ្តល់សេវាបង់ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឱ្យមានប្រសិទ្ធភាព សង្គតិភាព តម្លាភាព និងកាន់តែងាយស្រួល ឆាប់រហ័ស ជូនប្រជាពលរដ្ឋប្រកប ដោយការទទួលខុសត្រូវខ្ពស់ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដូចខាងក្រោម ÷

### I- នីតិវិធីនៃការបង់ពន្ធ

នៅពេលដែលយានយន្តត្រូវបានលក់ ឬផ្ទេរកម្មសិទ្ធិ ពីម្ចាស់មួយទៅម្ចាស់មួយទៀត កម្មសិទ្ធិករមានកាតព្វកិច្ចត្រូវបង់ពន្ធប្រថាប់ត្រា ៤% ស្របតាមច្បាប់ និងបញ្ញត្តិស្តីពីពន្ធដារ។

ដើម្បីបង់ពន្ធប្រថាប់ត្រា កម្មសិទ្ធិករត្រូវបំពេញពាក្យស្នើសុំបង់ពន្ធប្រថាប់ត្រាតាមទម្រង់ FORM VT 01 ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដោយត្រូវភ្ជាប់ជាមួយនូវសំណុំឯកសារផ្ទេរកម្មសិទ្ធិពីក្រសួងសាធារណការនិងដឹកជញ្ជូន ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ចដទៃទៀត និងឯកសារពាក់ព័ន្ធនានា ដូចមានរាយលម្អិតនៅក្នុងបញ្ជីរាយឯកសារតម្រូវ (Check List) សម្រាប់ភ្ជាប់មកជាមួយសំណើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត ដូចមានក្នុងឧបសម្ព័ន្ធ២ ដើម្បីចុះលេខបាកូដ (Barcode) នៅរដ្ឋបាលសារពើពន្ធ និងបង់ប្រាក់ពន្ធប្រថាប់ត្រានៅអគ្គនាយកដ្ឋានពន្ធដារ សម្រាប់រាជធានីភ្នំពេញ និងនៅសាខាពន្ធដារខេត្ត សម្រាប់ខេត្ត។

អ្នកជាប់ពន្ធអាចអញ្ជើញមកយកពាក្យស្នើសុំបង់ពន្ធប្រថាប់ត្រាទម្រង់ FORM VT 01 នៅរដ្ឋបាលសារពើពន្ធ ឬនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត ឬអាចទាញយក (Download) ពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ (http://www.tax.gov.kh/download.php) ឬអាចស្នើសុំតាមរយៈ (Email: vttinfo@tax.gov.kh) ឬតាមរយៈ WhatsApp ឬ Telegram ឬ Line ដែលមានលេខទូរស័ព្ទ 092 031 025 ដូចមានក្នុងឧបសម្ព័ន្ធ១។

### II. ការលើកលែងពន្ធប្រថាប់ត្រា សម្រាប់មធ្យោបាយដឹកជញ្ជូន

ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត ត្រូវបានលើកលែង ដូចខាងក្រោម ÷

១- ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទ ដែលមានកម្លាំងដល់១៥០សេះ

២- ការទទួលកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូនឬយានយន្ត ដែលត្រូវកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ននានានៃព្រះរាជាណាចក្រកម្ពុជា

៣- ការទទួលកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូន ឬយានយន្តរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា

៤- ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ។ ដោយឡែក ការទិញមធ្យោបាយដឹកជញ្ជូន ឬយានយន្តដែលបានចុះបញ្ជីនៅក្រសួងសាធារណការនិងដឹកជញ្ជូន ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ចដទៃទៀត មិនត្រូវបានលើកលែងពន្ធប្រថាប់ត្រានេះទេ។

ចំពោះការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ មិនតម្រូវឱ្យយកឯកសារមកបំពេញនីតិវិធីនៅរដ្ឋបាលសារពើពន្ធនោះទេ។

## III. **ការផ្តល់សេវា**

បន្ទាប់ពីរដ្ឋបាលសារពើពន្ធបានទទួលសំណុំឯកសារសម្រាប់ស្នើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្តគ្រប់គ្រាន់រួចហើយ ដំណើរការនៃការផ្ញើឯកសារជូនកម្មសិទ្ធិករត្រូវប្រើរយៈពេលពី ០២ថ្ងៃ ដល់ ០៥ថ្ងៃ នៃថ្ងៃធ្វើការ ដូចមានចែងក្នុងប្រកាសលេខ ១១៤៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រាល់ឯកសារដែលបានទទួល រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ពីការទទួលឯកសារដូចមានក្នុងឧបសម្ព័ន្ធ៣ មួយច្បាប់ ជូនកម្មសិទ្ធិករ ដែលមានលេខបាកូដ (Barcode) សម្រាប់សម្គាល់ឯកសារផ្ទេរកម្មសិទ្ធិយានយន្ត។ កម្មសិទ្ធិករអាចតាមដានឯកសារនេះ ថាតើដំណើការឯកសាររបស់ខ្លួនដល់ណាហើយ ដោយគ្រាន់តែថតឯកសារ និងលេខបាកូដ (Barcode) រួចបញ្ជូនមករដ្ឋបាលសារពើពន្ធ តាមរយៈ (Email: vttinfo@tax.gov.kh) ឬ WhatsApp ឬ Telegram ឬ Line ដែលមានលេខទូរស័ព្ទ 092 031 025 ឬអាចទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ (Hotline) 023 884 860 ឬអញ្ជើញមករដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវលិខិតដែលមានលេខសម្គាល់បាកូដ ដើម្បីទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធនេះ។

រដ្ឋបាលសារពើពន្ធនឹងធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដើម្បីផ្តល់ភាពងាយស្រួលដល់ម្ចាស់យានយន្ត ក្នុងការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ឬពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត នេះនៅថ្ងៃក្រោយ ដោយពុំចាំបាច់បំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវពាក់ព័ន្ធនឹងម្ចាស់កម្មសិទ្ធិយានយន្ត នោះទេ គឺគ្រាន់តែភ្ជាប់មកជាមួយនូវប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ និងបំពេញព័ត៌មានអ្នកទទួលកម្មសិទ្ធិថ្មី និងភ្ជាប់ឯកសារពាក់ព័ន្ធនានា ដូចមានរាយលម្អិតនៅក្នុងបញ្ជីរាយឯកសារតម្រូវ (Check List)។ សម្រាប់ការធ្វើប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទនេះ តម្រូវឱ្យបង់កម្រៃសេវា ៥ ០០០ រៀល តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

<u>បញ្ជាក់</u> ÷ អគ្គនាយកដ្ឋានពន្ធដារនឹងមិនទទួលខុសត្រូវចំពោះការយឺតយ៉ាវដែលកើតមានឡើង ដោយកម្មសិទ្ធិករមិនបានបំពេញកាតព្វកិច្ចក្នុងករណីដូចខាងក្រោមនេះ ÷

- មិនបានផ្តល់ឯកសារគ្រប់គ្រាន់តាមលក្ខខណ្ឌខាងលើ ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃប្រាក់ពន្ធដែលត្រូវបង់
- មិនទាន់បានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ចំពោះឆ្នាំដែលបានខកខាន
- មិនទាន់ឯកភាពនឹងប្រាក់ពន្ធដែលត្រូវបង់តាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ហើយនៅតែទាមទារតាមអ្វីដែលខ្លួនចង់បង់ ដែលមានតម្លៃទាបជាងមូលដ្ឋានគិតពន្ធ ដែលបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីណែនាំនេះត្រូវបានដាក់ឲ្យអនុវត្តចាប់ពីថ្ងៃ បានចុះហត្ថលេខានេះតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**កន្លែងទទួល ÷**

- សាលារាជធានី-ខេត្ត
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត
  “ដើម្បីសហការអនុវត្ត”
- នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
- សាខាពន្ធដារខេត្ត-ខណ្ឌ
  “ដើម្បីមុខការ”
- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ឧបសម្ព័ន្ធ I

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

☐ នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ (សម្រាប់រាជធានីភ្នំពេញ) Department of Law, Litigation and Statistics
☐ សាខាពន្ធដារ Tax Branch

សម្រាប់បិទបាកូដ
Stick barcode here!

**ទម្រង់ FORM VT 01**

# ពាក្យស្នើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត
## APPLICATION FOR VEHICLE TRANSFER TAX

## I. ព័ត៌មានយានយន្ត / VEHICLE DETAILS

| | |
|---|---|
| ស្លាកលេខ Plate No. | ភ្នំពេញ - 2 A - 5 7 X X |
| ម៉ាក Brand | LUXUS RX330 |
| ប្រភេទ Type | រថយន្តទេសចរណ៍ |
| ពណ៌ Color | ខ្មៅ |
| លេខម៉ាស៊ីន Engine No. | 3XXZ4213700 |
| លេខតួ Frame No. | 2XXGA31U34C852800 |
| លេខសាក់ស៊ី Chassis No. | NIL |
| កម្លាំង H.Power | 230 |
| ឆ្នាំផលិត Year | 2004 |
| ចំនួនភ្លៅ No. of Axles | 2 |
| ចំនួនស៊ីឡាំង No. of cylinders | 6 |
| ទំហំស៊ីឡាំង Cylinders disp. | 3300 |

សម្រាប់រថយន្តដឹកទំនិញ ឬអ្នកដំណើរ / For trucks or vans only

| ចំនួនកៅអី Number of seats | ចំនួនកង់ wheel | ទម្ងន់សរុប Weight |
|---|---|---|
| | | Kg |

## II. ព័ត៌មានអ្នកលក់ និង អ្នកទិញ / SELLER & BUYER DETAILS

| | ១. ព័ត៌មានអ្នកលក់ / Seller Details | ២. ព័ត៌មានអ្នកទិញ / Buyer Details |
|---|---|---|
| ឈ្មោះ ឬឈ្មោះក្រុមហ៊ុន Name or company name | សុខ ណាខន | កៅ សំបូរ |
| ឈ្មោះអក្សរឡាតាំង Name or company name in Latin | SOK NAKORN | KAO SAMBO |
| ☐ នីតិបុគ្គល Legal Person / លេខអត្តសញ្ញាណកម្មសារពើពន្ធ Tax Identification Number (TIN) | | |
| ☑ រូបវន្តបុគ្គល Physical Person / ថ្ងៃខែឆ្នាំកំណើត Date of birth | 03 02 1982 | 06 08 1980 |
| ☑ លេខអត្តសញ្ញាណប័ណ្ណ Identification card number / ☐ លេខលិខិតឆ្លងដែន Passport number | 190205XXX | 021522XXX |
| ផ្ទះលេខ/អគារ House Nº./Building | 5 | 20 |
| ផ្លូវ Street | 132 | លំ |
| ភូមិ Village | 1 | 3 |
| ឃុំ/សង្កាត់ Commune | ទឹកល្អក់ ១ | ច្រាំងចំរេះទី ១ |
| ក្រុង/ស្រុក/ខណ្ឌ District | ទួលគោក | ឫស្សីកែវ |
| ខេត្ត/រាជធានី Province/City | ភ្នំពេញ | ភ្នំពេញ |
| សារអេឡិចត្រូនិក Email | soknakorn@gmail.com | kaosambo@gmail.com |
| ទូរស័ព្ទចល័ត Mobile phone | 0125007xx | 0176206xx |
| ទូរស័ព្ទលើតុ Office telephone | | |

ប្រភេទផ្ទេរសិទ្ធិ Kinds of transfer: ☐ ទិញ-លក់ Buy - sell ☐ អំណោយ Gift ☐ ផ្សេងៗ Others

បើជាអំណោយ ពុំចាំបាច់បំពេញព័ត៌មានខាងក្រោមទេ
If gift, no need to fill any information below

ថ្ងៃខែឆ្នាំលក់យានយន្ត Date of sale: 23 05 2016

### សេចក្តីប្រកាស / DECLARATION

ខ្ញុំបាទ/នាងខ្ញុំ សូមធានាថារាល់ឯកសារ និងព័ត៌មានដែលបានបំពេញខាងលើ និងភ្ជាប់នៅក្នុងពាក្យស្នើសុំនេះ ពិតជាត្រឹមត្រូវ។ I declare that the information provided in this application including all attachments is true and correct.

### តម្លៃត្រូវបង់ / PAYMENT

| តម្លៃយានយន្ត Vehicle price | | អត្រាពន្ធ ៤% Tax rate 4% | | តម្លៃសរុប Tax amount |
|---|---|---|---|---|
| 8,000,000 R | x | 4% | = | 320,000 R |

### សម្រាប់មន្ត្រីពន្ធដារ / Tax official use only

កាលបរិច្ឆេទ Date: ថ្ងៃ ខែ ឆ្នាំ

| តម្លៃយានយន្ត Vehicle price | | អត្រាពន្ធ ៤% Tax rate 4% | | តម្លៃសរុប Tax amount |
|---|---|---|---|---|
| | x | | = | |

ហត្ថលេខា Signature

ឈ្មោះ Name

តួនាទី Position

លេខសម្គាល់មន្ត្រី ID number

### អ្នកស្នើសុំ / APPLICANT

កាលបរិច្ឆេទ Date: 25 05 2016

ហត្ថលេខា Signature

ឬស្នាមមេដៃ or thumb print

ឈ្មោះ Name

Sample only

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ឧបសម្ព័ន្ធ II

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# បញ្ជីរាយឯកសារតម្រូវសម្រាប់ភ្ជាប់មកជាមួយសំណើសុំ
# បង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត

## ១- រាយមុខលិខិតភ្ជាប់

| សំណុំឯកសារភ្ជាប់ | | | ច្បាប់ដើម | | ច្បាប់ថតចម្លង | | បរិយាយ |
|---|---|---|---|---|---|---|---|
| ប្រភេទប័ណ្ណ ឬឯកសារភ្ជាប់ | លេខប័ណ្ណ | កាលបរិច្ឆេទចុះ | មាន | គ្មាន | មាន | គ្មាន | |
| ១. ពាក្យស្នើសុំបង់ពន្ធប្រថាប់ត្រា FORM TV 01 | | | ✓ | | | | |
| ២. ប័ណ្ណសម្គាល់យានយន្ត ឬពាក្យសុំធ្វើទុតិយតា (ករណីបាត់ប័ណ្ណសម្គាល់យានយន្ត) | | | ✓ | | | | |
| ៣. លិខិតលក់ ឬកិច្ចសន្យាធានា | | | ✓ | | | | |
| ៤. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែន ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ | | | | | ✓ | | |
| ៥. ប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រអាករតម្លៃបន្ថែម (ករណីអ្នកលក់ឬអ្នកទិញជានីតិបុគ្គល) | | | | | ✓ | | |
| ៦. លិខិតជំរះបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ន | | | ✓ | | | | |
| ៧. ពាក្យសុំប្តូរពណ៌ ឬម៉ាស៊ីនយានយន្ត (ប្រសិនបើមាន) | | | ✓ | | | | |
| ៨. វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត | | | ✓ | | | | |

កាលបរិច្ឆេទ [ ថ្ងៃ ] [ ខែ ] [ ឆ្នាំ ]
ហត្ថលេខា
អ្នកស្នើសុំ
ឈ្មោះ

កាលបរិច្ឆេទ [ ថ្ងៃ ] [ ខែ ] [ ឆ្នាំ ]
ហត្ថលេខា
អ្នកផ្ទៀងផ្ទាត់
និងទទួល
ឈ្មោះ

Sample only

* សម្គាល់៖

ឧបសម្ព័ន្ធ III

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

2162019552

# លិខិតបញ្ជាក់ពីការទទួលឯកសារសម្រាប់ស្នើសុំបង់ពន្ធប្រថាប់ត្រា លើការផ្ទេរកម្មសិទ្ធិយានយន្ត

## ១. ព័ត៌មានអ្នកស្នើសុំ

| | | | |
|---|---|---|---|
| ឈ្មោះអ្នកកាន់ឯកសារ៖ | ចាន់ សុផល | លេខទូរស័ព្ទ៖ | 017200500 |
| ប្រភេទរថយន្ត៖ | រថយន្តទេសចរណ៍ | ស្លាកលេខ៖ | ភ្នំពេញ 2H-3349 |
| ម៉ាក៖ | LEXUS RX300 | | |
| កាលបរិច្ឆេទស្នើសុំ៖ | 19-05-2016 08:59:12 | | |

## ២. សំណុំឯកសារភ្ជាប់

| ល.រ | សំណុំឯកសារភ្ជាប់ |
|---|---|
| 1 | ពាក្យស្នើសុំប្រកាសបង់ពន្ធ ផ្ទេរកម្មសិទ្ធិយានយន្ត |
| 2 | ប័ណ្ណសម្គាល់យានយន្ត |
| 3 | លិខិត លក់ |
| 4 | លិខិតប្រកាស |
| 5 | លិខិតសម្គាល់ខ្លួនអ្នកផ្ទេរសិទ្ធិ |
| 6 | លិខិតសម្គាល់ខ្លួនអ្នកទទួលសិទ្ធិ |
| 7 | វិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត |
| សរុប | 7 |

ភ្នំពេញ ថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2016

| ហត្ថលេខាអ្នកទទួល | ហត្ថលេខាអ្នកស្នើសុំ |
|---|---|
| សឿ ទិញ | ចាន់ សុផល |

Sample only